ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:.....០១២/១៧..គ.ម.ក./ប្រក

# ប្រកាស
# ស្ដីពី
# ការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622
Website : www.secc.gov.kh

**សម្រេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការផ្សះផ្សា និងការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ដែលធ្វើឡើងដោយគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

-**ច្បាប់** សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-**ពាក្យបណ្តឹង** សំដៅដល់ពាក្យបណ្តឹងសុំការផ្សះផ្សា ឬពាក្យបណ្តឹងសុំការដោះស្រាយវិវាទ អនុលោមតាមប្រកាសនេះ។

-**ភាគីជម្លោះ** សំដៅដល់ភាគីជម្លោះណាមួយ ឬភាគីជម្លោះទាំងសងខាងដែលកំពុងមានវិវាទ។

-**វិវាទ ឬវិវាទក្នុងវិស័យមូលបត្រ** សំដៅដល់គ្រប់ការទាមទារ ជម្លោះ ឬទំនាស់ពាក់ព័ន្ធនឹងមូលបត្រ ឬការផ្តល់សេវាក្នុងវិស័យមូលបត្រ។

-**វេទិកាមជ្ឈត្តកម្ម** សំដៅដល់មជ្ឈត្តករមួយនាក់ ឬមួយក្រុម ដែលបានចុះបញ្ជីនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឬនៅក្រៅបញ្ជី។ ឈ្មោះមជ្ឈត្តករដែលទទួលបានការបណ្តុះបណ្តាលក្នុងវិស័យមូលបត្រពី **គ.ម.ក.** អាចត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមគេហទំព័ររបស់ **គ.ម.ក.** និង/ឬប្រព័ន្ធផ្សព្វ-ផ្សាយជាសាធារណៈផ្សេងទៀត។

-**អនុក្រឹត្យ** សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-**អ្នកផ្សះផ្សា** សំដៅដល់មន្ត្រីរបស់ **គ.ម.ក.** ដែលត្រូវបានចាត់តាំង ដើម្បីផ្សះផ្សាវិវាទនៅក្នុងវិស័យមូលបត្រ។

-**អ្នកដោះស្រាយវិវាទ** សំដៅដល់មន្ត្រីរបស់ **គ.ម.ក.** ដែលត្រូវបានចាត់តាំងដោយអគ្គនាយកនៃ **គ.ម.ក.** ដើម្បីដោះស្រាយវិវាទនៅក្នុងវិស័យមូលបត្រ។

## ជំពូកទី ២
## ពាក្យបណ្តឹងសុំការផ្សះផ្សា

**ប្រការ ៣.-**

ភាគីជម្លោះអាចដាក់ពាក្យបណ្តឹងសុំការផ្សះផ្សាជូនទៅ **គ.ម.ក.** តាមរយៈនាយកដ្ឋានកិច្ចការគតិយុត្ត នៃ **គ.ម.ក.**។

**ប្រការ ៤.-**

ភាគីជម្លោះដែលដាក់ពាក្យបណ្តឹងត្រូវមានសមត្ថភាពដោយខ្លួនឯង ឬដោយអ្នកតំណាង ស្របតាមបញ្ញត្តិនៃច្បាប់ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៥.-**

ពាក្យបណ្តឹងត្រូវបញ្ជាក់ឱ្យបានច្បាស់យ៉ាងហោចណាស់នូវចំណុចដូចខាងក្រោម÷

១- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីជម្លោះ។

២- កម្មវត្ថុនៃបណ្តឹង និងខ្លឹមសារនៃការទាមទារ។

៣- អង្គហេតុ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

ក្នុងករណីចាំបាច់ នាយកដ្ឋានកិច្ចការគតិយុត្តអាចស្នើឱ្យភាគីជម្លោះផ្តល់នូវឯកសារ ឬព័ត៌មានបន្ថែម និងភ្ជាប់មកជាមួយនូវឯកសារបកប្រែជាភាសាខ្មែរ ក្នុងករណីឯកសារដើមជាភាសាបរទេស។

ករណីដែលពាក្យបណ្តឹងមានព័ត៌មានមិនគ្រប់គ្រាន់ ឬមិនសមស្រប នាយកដ្ឋានកិច្ចការគតិយុត្តត្រូវបង្គាប់ឱ្យកែតម្រូវចំណុចខ្វះក្នុងពាក្យបណ្តឹងនោះក្នុងរយៈពេល ៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃអ្នកដាក់ពាក្យបណ្តឹងទទួលបានការជូនដំណឹងឱ្យកែតម្រូវនោះ។

**ប្រការ ៦.-**

ពាក្យបណ្តឹងត្រូវបានបដិសេធ ក្នុងករណីណាមួយដូចខាងក្រោម÷

១- កម្មវត្ថុនៃពាក្យបណ្តឹងមិនពាក់ព័ន្ធនឹងវិវាទក្នុងវិស័យមូលបត្រ។

២- ពាក្យបណ្តឹងដែលមានព័ត៌មានមិនគ្រប់គ្រាន់ ឬមិនសមស្រប។

៣- ពាក្យបណ្តឹងដែលអ្នកប្តឹងគ្មានសមត្ថភាព ឬមិនមានផលប្រយោជន៍ក្នុងវិវាទ។

៤- ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងបទល្មើស។

៥- ពាក្យបណ្តឹងដែលកំពុង ឬត្រូវបានដោះស្រាយដោយមជ្ឈត្តការ ឬតុលាការ។

៦- សិទ្ធិប្តឹងត្រូវបានរលត់ដោយផុតអាជ្ញាយុកាល។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងអំពីការបដិសេធលើពាក្យបណ្តឹងនេះទៅភាគីជម្លោះដែលដាក់ពាក្យបណ្តឹង។

**ប្រការ ៧.-**

ករណីពាក្យបណ្តឹងត្រូវបានបំពេញត្រឹមត្រូវ និងគោរពតាមលក្ខខណ្ឌដូចមានចែងនៅក្នុងប្រកាសនេះ ការិយាល័យទទួលបន្ទុកដោះស្រាយវិវាទនៃនាយកដ្ឋានកិច្ចការគតិយុត្ត ដែលជាមជ្ឈមណ្ឌលដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ត្រូវទាក់ទងទៅគ្រប់ភាគីជម្លោះ ដើម្បីឱ្យភាគីជម្លោះចុះកិច្ចព្រមព្រៀងផ្សះផ្សាវិវាទ ទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

មុនចាប់ផ្តើមដំណើរការផ្សះផ្សា ភាគីជម្លោះត្រូវបង់កម្រៃសេវារដ្ឋបាល ដាក់ប្រាក់តម្កល់សម្រាប់ទូទាត់សោហ៊ុយចំណាយផ្សេងៗនៅក្នុងដំណើរការផ្សះផ្សា ព្រមទាំងបង់កម្រៃសេវាសម្រាប់អ្នកផ្សះផ្សាដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។ កម្រៃសេវារដ្ឋបាល ប្រាក់តម្កល់ និងកម្រៃសេវាសម្រាប់អ្នកផ្សះផ្សានេះត្រូវបង់ដោយភាគីជម្លោះក្នុងចំណែកស្មើៗគ្នា លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយភាគីជម្លោះ។ ប៉ុន្តែករណីអ្នកដាក់ពាក្យបណ្តឹងជាវិនិយោគិន កម្រៃសេវារដ្ឋបាល ប្រាក់តម្កល់ និងកម្រៃសេវាសម្រាប់អ្នកផ្សះផ្សានេះត្រូវជាបន្ទុកទាំងស្រុងរបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

## ជំពូកទី ៣
## ភាគីជម្លោះ

**ប្រការ ៨.-**

ភាគីជម្លោះមានសិទ្ធិដូចខាងក្រោម÷

១- រៀបរាប់អង្គហេតុ និងដាក់បន្ថែមឯកសារសំខាន់នានា។

២- លើកសំណូមពរ និងយោបល់ផ្សេងៗក្នុងដំណើរការនីតិវិធី។

៣- ស្នើសុំដាក់បញ្ចូលអ្នកបកប្រែភាសា ក្នុងករណីចាំបាច់។

៤- ស្នើសុំពន្យារពេលការផ្សះផ្សា ឬការដោះស្រាយវិវាទ ដោយមានបញ្ជាក់មូលហេតុសមស្រប។

៥- ស្នើសុំថតចម្លងកំណត់ហេតុនៃលទ្ធផលផ្សះផ្សា។

៦- សិទ្ធិផ្សេងទៀតដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ ៩.-**

ភាគីជម្លោះមានកាតព្វកិច្ចដូចខាងក្រោម÷

១- ចូលរួមក្នុងនីតិវិធីនៃការផ្សះផ្សា ឬដោះស្រាយវិវាទ ដោយមានភាពស្មោះត្រង់ សីលធម៌ និងអាកប្បកិរិយាសមរម្យ ព្រមទាំងអនុវត្តតាមវិធាននៃការផ្សះផ្សា និងការដោះស្រាយវិវាទ។

២- សហការជាមួយអ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទ និងភាគីជម្លោះផ្សេងទៀត។

៣- អនុវត្តនូវគ្រប់ចំណុចដែលបានព្រមព្រៀងនៅក្នុងការផ្សះផ្សា ឬការដោះស្រាយវិវាទ។

៤- អនុវត្តយ៉ាងយកចិត្តទុកដាក់នូវខ្លឹមសារ និងលក្ខខណ្ឌនានាដែលបញ្ញត្តិនៅក្នុងប្រកាសនេះ។

**ប្រការ ១០.-**

ភាគីជម្លោះដែលប្ដឹងទាមទារអាចដកពាក្យបណ្ដឹងរបស់ខ្លួន ឬព្រមព្រៀងជាមួយភាគីជម្លោះម្ខាងទៀតដកខ្លួនចេញពីការផ្សះផ្សា ឬការដោះស្រាយវិវាទបានគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយកនៃ **គ.ម.ក.** តាមរយៈការិយាល័យទទួលបន្ទុកដោះស្រាយវិវាទ។

# ជំពូកទី ៤

# ការផ្សះផ្សាវិវាទ

## ផ្នែកទី ១

## អ្នកផ្សះផ្សា

**ប្រការ ១១.-**

អ្នកផ្សះផ្សា ១ (មួយ) រូប ឬច្រើនរូប ប៉ុន្តែមិនត្រូវលើសពី ៣ (បី) រូប ត្រូវចាត់តាំងដោយអគ្គនាយកនៃ **គ.ម.ក.** តាមសំណើរបស់ប្រធានការិយាល័យទទួលបន្ទុកដោះស្រាយវិវាទ។

**ប្រការ ១២.-**

អ្នកផ្សះផ្សាមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

១- សាកសួរភាគីជម្លោះដើម្បីស្វែងរកចំណុចវិវាទ។

២- កំណត់នូវចំណុចវិវាទ និងពិចារណាពីវិធីសាស្ត្រសម្រាប់ការផ្សះផ្សា។

៣- បង្កភាពងាយស្រួលដល់ភាគីជម្លោះ ក្នុងការចរចាដោយសន្តិវិធី។

៤- បង្កើតជម្រើសផ្សេងៗដែលជាដំណោះស្រាយសម្រាប់ឱ្យភាគីជម្លោះពិចារណាដើម្បីសះជា។

៥- លើកទឹកចិត្ត និងជំរុញភាគីជម្លោះឈានទៅដល់ការព្រមព្រៀងគ្នាតាមដែលអាចធ្វើទៅបាន។

៦- អនុវត្តមុខងារ និងភារកិច្ចដោយត្រឹមត្រូវ ស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងវិធាននៃការផ្សះផ្សា។

៧- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតដែលមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ១៣.-**

អ្នកផ្សះផ្សាមានសិទ្ធិអំណាចដូចខាងក្រោម÷

១- រៀបចំកិច្ចប្រជុំផ្សះផ្សា ដោយអាចជួបប្រជុំជាមួយភាគីជម្លោះទាំងអស់ ឬជាមួយភាគីជម្លោះដាច់ដោយឡែកពីគ្នា។

២- ប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិវាទពីភាគីជម្លោះ។

៣- ស្នើឱ្យមានអ្នកបកប្រែភាសា អ្នកជំនាញ និងបុគ្គលពាក់ព័ន្ធផ្សេងៗទៀត ប្រសិនបើចាំបាច់។

៤- ពន្យារពេលកិច្ចប្រជុំផ្សះផ្សា ដើម្បីអនុញ្ញាតឱ្យភាគីជម្លោះអាចពិចារណាលើសំណើជាក់លាក់ណាមួយ ឬដើម្បីប្រមូលនូវរាល់ព័ត៌មាន ឬគំនិតយោបល់ផ្សេងៗ ក្នុងករណីចាំបាច់។

៥- សិទ្ធិអំណាចផ្សេងទៀតដែលមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ១៤.-**

មិនអាចអនុវត្តមុខងារជាអ្នកផ្សះផ្សាបានឡើយ ប្រសិនបើអ្នកផ្សះផ្សានោះ÷

១-ជា ឬធ្លាប់ជាសហព័ទ្ធនៃភាគីជម្លោះ។

២-ជាញាតិលោហិតរហូតដល់ថ្នាក់ទី៤ ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគីជម្លោះណាមួយ។

៣-ធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីជម្លោះ។

៤-ជាបុគ្គលដែលមានផលប្រយោជន៍ក្នុងវិវាទ។

៥-ធ្លាប់ជាសាក្សី ឬជាអ្នកតំណាង ឬជាអ្នកជំនាញផ្តល់ប្រឹក្សាឱ្យភាគីជម្លោះ។

៦-ស្ថិតក្នុងស្ថានភាពណាមួយដែលលេចចេញនូវភាពលំអៀង ឬទំនាស់ផលប្រយោជន៍។

បុគ្គលដែលត្រូវបានចាត់តាំងជាអ្នកផ្សះផ្សាត្រូវជូនដំណឹងជាបន្ទាន់ទៅអគ្គនាយកនៃ **គ.ម.ក.** តាមរយៈការិយាល័យទទួលបន្ទុកដោះស្រាយវិវាទ នៅពេលមានភាពជាប់ពាក់ព័ន្ធនឹងស្ថានភាពណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ។

**ប្រការ ១៥.-**

អគ្គនាយកនៃ **គ.ម.ក.** អាចចាត់តាំងអ្នកផ្សះផ្សាថ្មី តាមសំណើរបស់ប្រធានការិយាល័យទទួលបន្ទុកដោះស្រាយវិវាទ ក្នុងករណីដូចខាងក្រោម÷

១-ករណីមានការស្នើសុំដកខ្លួនរបស់អ្នកផ្សះផ្សា ដោយសារមានកាលៈទេសៈណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ ១៤ នៃប្រកាសនេះ។

២-ករណីមានការស្នើសុំផ្លាស់ប្តូរអ្នកផ្សះផ្សាពីភាគីជម្លោះ ដោយសារមានកាលៈទេសៈណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ ១៤ នៃប្រកាសនេះ។

៣-ករណីមានកាលៈទេសៈណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ ១៤ នៃប្រកាសនេះ ឬហេតុការណ៍ណាមួយដូចមានចែងក្នុងចំណុចទី១ នៃប្រការ ១៩ នៃប្រកាសនេះ។

## ផ្នែកទី ២
## ដំណើរការនីតិវិធី និងការបញ្ចប់ការផ្សះផ្សា

**ប្រការ ១៦.-**

អ្នកផ្សះផ្សាត្រូវអញ្ជើញភាគីជម្លោះទាំងអស់តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀតតាមការចាំបាច់ ឱ្យចូលរួមនៅក្នុងដំណើរការផ្សះផ្សា តាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់ដោយអ្នកផ្សះផ្សា។ ប្រសិនបើភាគីជម្លោះមិនបានចូលរួមក្នុងដំណើរការផ្សះផ្សាតាមការអញ្ជើញទេ អ្នកផ្សះផ្សាត្រូវធ្វើការអញ្ជើញជាលើកទី២ និងបន្តបន្ទាប់ទៅតាមការចាំបាច់។

**ប្រការ ១៧.-**

កិច្ចប្រជុំផ្សះផ្សាត្រូវធ្វើឡើងដោយសម្ងាត់ ហើយមានតែអ្នកផ្សះផ្សា និងភាគីជម្លោះតែប៉ុណ្ណោះត្រូវបានអនុញ្ញាតឱ្យមានវត្តមាននៅក្នុងកិច្ចប្រជុំផ្សះផ្សានេះ។

អ្នកបកប្រែភាសា និងអ្នកជំនាញអាចមានវត្តមាននៅក្នុងនីតិវិធីផ្សះផ្សា ប្រសិនបើអ្នកផ្សះផ្សាយល់ថាអាចជួយដល់ដំណើរការផ្សះផ្សាបាន។ អ្នកបកប្រែ និងអ្នកជំនាញទាំងនោះត្រូវចុះកិច្ចព្រមព្រៀងរក្សាការសម្ងាត់ទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

អ្នកផ្សះផ្សាអាចជួបប្រជុំជាមួយភាគីជម្លោះទាំងអស់ ឬជាមួយភាគីជម្លោះដាច់ដោយឡែកពីគ្នា ដោយផ្តល់ពេលវេលាសមស្របដល់ភាគីជម្លោះ និងត្រូវធ្វើកំណត់ហេតុ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយអ្នកផ្សះផ្សា និងត្រូវចុះហត្ថលេខា ឬផ្ដិតមេដៃដោយភាគីជម្លោះ។

ការផ្សះផ្សាត្រូវប្រើភាសាខ្មែរ លើកលែងមានការយល់ព្រមប្រើប្រាស់ភាសាផ្សេងដោយអ្នកផ្សះផ្សា។

**ប្រការ ១៨.-**

ប្រសិនបើភាគីជម្លោះណាមួយមិនបានមកបង្ហាញខ្លួនចំនួន ២ (ពីរ) លើកជាប់ៗគ្នានៅក្នុងដំណើរការផ្សះផ្សាដោយគ្មានមូលហេតុសមរម្យ ការផ្សះផ្សានេះអាចចាត់ទុកថាមិនសះជា។

**ប្រការ ១៩.-**

នីតិវិធីនៃការផ្សះផ្សាត្រូវផ្អាក ឬបង្អង់ ពេលមានហេតុណាមួយដូចខាងក្រោម៖

១-ការដកខ្លួន ការផ្លាស់ប្តូរ ការបាត់បង់សមត្ថភាព ឬមរណភាពរបស់អ្នកផ្សះផ្សា លើកលែងករណីអ្នកផ្សះផ្សាមានចំនួនច្រើន ហើយអាចបន្តនីតិវិធីផ្សះផ្សាបាន។

២-ការបាត់បង់សមត្ថភាព ឬមរណភាព របស់ភាគីជម្លោះ។

៣-ការរំលត់នីតិបុគ្គលដែលជាភាគីជម្លោះដោយការរួមបញ្ចូលគ្នា។

៤-ករណីប្រធានសក្តិ។

៥-ករណីផ្សេងទៀតដែលអគ្គនាយកនៃ **គ.ម.ក.** យល់ថាប៉ះពាល់ដល់ដំណើរការផ្សះផ្សា។

រយៈពេលនៃការផ្សះផ្សាដូចមានចែងក្នុងប្រការ ២១ នៃប្រកាសនេះ ត្រូវផ្អាក ឬបង្អង់រហូតដល់ពេលដែលនីតិវិធីនៃការផ្សះផ្សាត្រូវចាប់ផ្តើមឡើងវិញ។

**ប្រការ ២០.-**

ការផ្សះផ្សាត្រូវបញ្ចប់ ក្នុងករណីដូចខាងក្រោម៖

១-ភាគីជម្លោះសះជានឹងគ្នា។

២-ភាគីជម្លោះបានព្រមព្រៀងគ្នាដកខ្លួនចេញពីការផ្សះផ្សា។

៣-ភាគីជម្លោះដែលប្តឹងទាមទារបានដកពាក្យបណ្តឹងវិញ។

៤-ភាគីជម្លោះទាំងអស់មិនមកចូលរួមក្នុងការផ្សះផ្សា ២ (ពីរ) ឬច្រើនដង ដោយគ្មានមូលហេតុ។

៥-អ្នកផ្សះផ្សា និងភាគីជម្លោះ ព្រមព្រៀងគ្នាបញ្ចប់ការផ្សះផ្សា ក្នុងករណីយល់ឃើញថាវិវាទមិនអាចធ្វើការផ្សះផ្សាតទៅទៀតបាន។

៦-ភាគីជម្លោះបំពានធ្ងន់ធ្ងរចំពោះបញ្ញត្តិដែលមានចែងក្នុងប្រកាសនេះ។

៧-ភាគីជម្លោះបានទទួលមរណភាព ឬបានរំលត់នីតិបុគ្គល ហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង។

**ប្រការ ២១.-**

ដំណើរការនៃការផ្សះផ្សាត្រូវបញ្ចប់ក្នុងរយៈពេលយ៉ាងយូរ ៩០ (កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលអ្នកផ្សះផ្សាត្រូវបានចាត់តាំងដោយអគ្គនាយកនៃ **គ.ម.ក.** លើកលែងករណីដូចខាងក្រោម÷

១-មានហេតុណាមួយដូចបញ្ញត្តិក្នុងប្រការ ១៩ នៃប្រកាសនេះ ឬ

២-មានការសម្រេចរបស់អគ្គនាយកនៃ **គ.ម.ក.** តាមសំណើសុំពន្យារពេលរបស់អ្នកផ្សះផ្សា ឬសំណើសុំពន្យារពេលតាមការព្រមព្រៀងរបស់ភាគីជម្លោះ។

**ប្រការ ២២.-**

ការព្រមព្រៀងរបស់ភាគីជម្លោះដែលធ្វើឡើងនៅចំពោះមុខអ្នកផ្សះផ្សា ជាការព្រមព្រៀងដែលមានអានុភាពអនុវត្ត។

ភាគីជម្លោះអាចព្រមព្រៀងគ្នារៀបចំកិច្ចព្រមព្រៀងសះជាដាច់ដោយឡែកនៅចំពោះមុខអ្នកផ្សះផ្សាដោយបញ្ចូលនូវខសន្យា និងលក្ខខណ្ឌផ្សេងៗបន្ថែមទៀតបាន។

**ប្រការ ២៣.-**

ចំពោះចំណុចនៃវិវាទដែលភាគីជម្លោះមិនបានព្រមព្រៀងគ្នា ត្រូវចាត់ទុកថាមិនសះជា។ អ្នកផ្សះផ្សាត្រូវរៀបចំធ្វើកំណត់ហេតុមិនសះជា ដោយបញ្ជាក់ពីចំណុចមិនសះជា មូលហេតុ និងព័ត៌មានចាំបាច់ផ្សេងទៀត។ កំណត់ហេតុមិនសះជាត្រូវមានកាលបរិច្ឆេទត្រឹមត្រូវ និងចុះហត្ថលេខាដោយអ្នកផ្សះផ្សា ហើយត្រូវចម្លងជូនគ្រប់ភាគីជម្លោះ។

ភាគីជម្លោះអាចប្ដឹងទៅវេទិកាដោះស្រាយវិវាទរបស់ **គ.ម.ក.** តាមនីតិវិធីដូចមានបញ្ញត្តិក្នុងជំពូកទី៥នៃប្រកាសនេះ ឬទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច ចំពោះចំណុចមិនសះជា។ អាជ្ញាយុកាលនៃបណ្ដឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច មានរយៈពេល ៩០ (កៅសិប)ថ្ងៃ គិតពីថ្ងៃភាគីជម្លោះទទួលបានកំណត់ហេតុមិនសះជា ពុំនោះទេ សិទ្ធិប្ដឹងនេះនឹងត្រូវបាត់បង់។

## ជំពូកទី ៥

## ការដោះស្រាយវិវាទ

### ផ្នែកទី ១

### ពាក្យបណ្ដឹងសុំការដោះស្រាយវិវាទ

**ប្រការ ២៤.-**

ភាគីជម្លោះដែលមិនសះជាក្នុងការផ្សះផ្សាដូចមានចែងក្នុងជំពូកទី ៤ ខាងលើ អាចដាក់ពាក្យបណ្ដឹងសុំការដោះស្រាយវិវាទជូនទៅ **គ.ម.ក.** តាមរយៈការិយាល័យទទួលបន្ទុកដោះស្រាយវិវាទ។

**ប្រការ ២៥.-**

ពាក្យបណ្ដឹងត្រូវបានបដិសេធ ក្នុងករណីណាមួយដូចខាងក្រោម÷

១-កម្មវត្ថុនៃបណ្តឹងមិនអាចគិតជាប្រាក់បាន។

២-កម្មវត្ថុនៃបណ្តឹងមានតម្លៃលើសពី ៤០០.០០០.០០០(បួនរយលាន) រៀល លើកលែងតែភាគីជម្លោះព្រមព្រៀងជាឯកច្ឆន្ទកម្រិតតម្លៃកម្មវត្ថុនៃបណ្តឹងមិនឱ្យលើសពី ៤០០.០០០.០០០(បួនរយលាន) រៀលវិញ។

៣-ពាក្យបណ្តឹងដែលកំពុង ឬត្រូវបានដោះស្រាយដោយមជ្ឈត្តការ ឬតុលាការ។

៤-វិវាទដែលមានរយៈពេលលើសពី ៩០ (កៅសិប) ថ្ងៃ គិតពីថ្ងៃភាគីជម្លោះទទួលបានកំណត់ហេតុមិនសះជាដូចមានចែងក្នុងប្រការ ២៣ នៃប្រកាសនេះ។

**ប្រការ ២៦.-**

មុនចាប់ផ្តើមដំណើរការដោះស្រាយវិវាទ ភាគីជម្លោះត្រូវចុះកិច្ចព្រមព្រៀងដោះស្រាយវិវាទតាមទម្រង់កំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** និងត្រូវបង់កម្រៃសេវារដ្ឋបាល ដាក់ប្រាក់តម្កល់សម្រាប់ទូទាត់សោហ៊ុយចំណាយផ្សេងៗនៅក្នុងដំណើរការដោះស្រាយវិវាទ ព្រមទាំងបង់កម្រៃសេវាសម្រាប់អ្នកដោះស្រាយវិវាទដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។ កម្រៃសេវារដ្ឋបាល ប្រាក់តម្កល់ និងកម្រៃសេវាសម្រាប់អ្នក-ដោះស្រាយវិវាទនេះ ត្រូវបង់ដោយភាគីជម្លោះក្នុងចំណែកស្មើៗគ្នា លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយភាគីជម្លោះ។

## ផ្នែកទី ២
## អ្នកដោះស្រាយវិវាទ

**ប្រការ ២៧.-**

អ្នកដោះស្រាយវិវាទ ១ (មួយ) រូប ឬ ៣ (បី) រូប ត្រូវចាត់តាំងដោយអគ្គនាយកនៃ **គ.ម.ក.** តាមសំណើរបស់ប្រធានការិយាល័យទទួលបន្ទុកដោះស្រាយវិវាទ។ ក្នុងករណីការដោះស្រាយវិវាទធ្វើឡើងដោយអ្នកដោះស្រាយវិវាទ ៣ (បី) រូប អគ្គនាយកនៃ **គ.ម.ក.** ត្រូវចាត់តាំងអ្នកដោះស្រាយវិវាទ ១ (មួយ) រូបធ្វើជាប្រធានក្រុម។ អ្នកផ្សះផ្សាក៏អាចត្រូវបានចាត់តាំងជាអ្នកដោះស្រាយវិវាទចំពោះករណីវិវាទដែលខ្លួនធ្លាប់ផ្សះផ្សា។

ការិយាល័យទទួលបន្ទុកដោះស្រាយវិវាទត្រូវជូនដំណឹងអំពីឈ្មោះ និងព័ត៌មានចាំបាច់ពាក់ព័ន្ធនឹងអ្នកដោះស្រាយវិវាទ ឬក្រុមអ្នកដោះស្រាយវិវាទដល់គ្រប់ភាគីជម្លោះទាំងអស់។

**ប្រការ ២៨.-**

អ្នកដោះស្រាយវិវាទមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

១-រៀបចំវេទិកាដោះស្រាយវិវាទ។

២-កំណត់នូវចំណុចវិវាទដែលត្រូវដោះស្រាយឱ្យបានច្បាស់លាស់។

៣-បង្កភាពងាយស្រួលឱ្យភាគីជម្លោះឈានទៅរកការសះជា។

៤-អនុវត្តមុខងារ និងភារកិច្ចដោយត្រឹមត្រូវតាមក្រមសីលធម៌វិជ្ជាជីវៈ និងវិធាននៃការដោះស្រាយវិវាទ។

៥-ចេញសេចក្តីសម្រេចលើវិវាទ។

៦-អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀត ដែលមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ២៩.-**

អ្នកដោះស្រាយវិវាទមានសិទ្ធិអំណាចដូចខាងក្រោម÷

១-ប្រមូលរាល់ឯកសារ និងព័ត៌មានពាក់ព័ន្ធដែលទទួលបានក្នុងដំណើរការផ្សះផ្សា។

២-ប្រមូលព័ត៌មានពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។

៣-តម្រូវឱ្យមានអ្នកបកប្រែភាសា និងអ្នកជំនាញ ប្រសិនបើចាំបាច់។

៤-សិទ្ធិអំណាចផ្សេងទៀតដែលមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ៣០.-**

មិនអាចអនុវត្តមុខងារជាអ្នកដោះស្រាយវិវាទបានឡើយ ប្រសិនបើអ្នកដោះស្រាយវិវាទនោះស្ថិតក្នុងកាលៈទេសៈណាមួយដូចមានចែងក្នុងចំណុចទី១ ដល់ចំណុចទី៦ នៃប្រការ ១៤ នៃប្រកាសនេះ។

បុគ្គលដែលត្រូវបានចាត់តាំងជាអ្នកដោះស្រាយវិវាទ ត្រូវជូនដំណឹងជាបន្ទាន់ទៅអគ្គនាយកនៃ **គ.ម.ក.** និងភាគីជម្លោះ នៅពេលមានភាពជាប់ពាក់ព័ន្ធនឹងស្ថានភាពណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ តាមរយៈការិយាល័យទទួលបន្ទុកដោះស្រាយវិវាទ។ បន្ទាប់ពីបានដឹង ឬទទួលបានដំណឹងអំពីភាពជាប់ពាក់ព័ន្ធនេះ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់តាំងអ្នកដោះស្រាយវិវាទថ្មី។

**ប្រការ ៣១.-**

ករណីមានការស្នើសុំដកខ្លួនពីអ្នកដោះស្រាយវិវាទ ឬមានការស្នើសុំផ្លាស់ប្តូរអ្នកដោះស្រាយវិវាទពីភាគីជម្លោះ ដោយសារមានកាលៈទេសៈណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ ៣០ នៃប្រកាសនេះ ឬហេតុការណ៍ណាមួយដូចមានចែងក្នុងចំណុចទី១ នៃប្រការ ៣៤ នៃប្រកាសនេះ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់តាំងអ្នកដោះស្រាយវិវាទថ្មី តាមសំណើរបស់ប្រធានការិយាល័យទទួលបន្ទុកដោះស្រាយវិវាទ ក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទសម្រេចផ្លាស់ប្តូរអ្នកដោះស្រាយវិវាទ។

## ផ្នែកទី ៣
## ដំណើរការនីតិវិធី និងការបញ្ចប់ការដោះស្រាយវិវាទ

**ប្រការ ៣២.-**

អ្នកដោះស្រាយវិវាទត្រូវអញ្ជើញភាគីជម្លោះទាំងអស់ឱ្យចូលរួមនៅក្នុងវេទិកាដោះស្រាយវិវាទ តាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់ដោយអ្នកដោះស្រាយវិវាទ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀត។ ប្រសិនបើភាគីជម្លោះមិនបានចូលរួមក្នុងវេទិកាដោះស្រាយវិវាទតាមការអញ្ជើញ អ្នកដោះស្រាយវិវាទអាចអញ្ជើញជាលើកទី២។

**ប្រការ ៣៣.-**

វេទិកាដោះស្រាយវិវាទត្រូវធ្វើឡើងដោយសម្ងាត់ ហើយមានតែអ្នកដោះស្រាយវិវាទ និងភាគីជម្លោះតែប៉ុណ្ណោះត្រូវបានអនុញ្ញាតឱ្យមានវត្តមាននៅក្នុងវេទិកានេះ។

ការដោះស្រាយវិវាទត្រូវប្រើភាសាខ្មែរ លើកលែងតែមានការយល់ព្រមប្រើប្រាស់ភាសាផ្សេងដោយអ្នកដោះស្រាយវិវាទ។

អ្នកបកប្រែភាសា អ្នកជំនាញ មេធាវី សាក្សី និងបុគ្គលពាក់ព័ន្ធផ្សេងទៀត អាចមានវត្តមាននៅក្នុងនីតិវិធីដោះស្រាយវិវាទ ប្រសិនបើអ្នកដោះស្រាយវិវាទយល់ថាចាំបាច់។ បុគ្គលដែលចូលរួមទាំងអស់នេះត្រូវចុះកិច្ចព្រមព្រៀងរក្សាការសម្ងាត់ ទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៤.-**

នីតិវិធីនៃការដោះស្រាយវិវាទត្រូវផ្អាក ឬបង្អង់ ពេលមានហេតុណាមួយដូចខាងក្រោម÷

១- ការដកខ្លួន ការផ្លាស់ប្តូរ ការបាត់បង់សមត្ថភាព ឬមរណភាព របស់អ្នកដោះស្រាយវិវាទ។

២-កាលៈទេសៈ ឬហេតុណាមួយដូចមានចែងក្នុងចំណុចទី២ ដល់ចំណុចទី៥ នៃប្រការ ១៩ នៃប្រកាសនេះ។

រយៈពេលនៃការដោះស្រាយវិវាទដូចមានចែងក្នុងប្រការ ៣៦ នៃប្រកាសនេះ ត្រូវផ្អាក ឬបង្អង់រហូតដល់ពេលដែលនីតិវិធីនៃការដោះស្រាយវិវាទត្រូវចាប់ផ្តើមឡើងវិញ។

**ប្រការ ៣៥.-**

ការដោះស្រាយវិវាទត្រូវបញ្ចប់ក្នុងករណីដូចខាងក្រោម÷

១-អ្នកដោះស្រាយវិវាទបានចេញសេចក្តីសម្រេចចំពោះវិវាទ។

២-ភាគីជម្លោះសះជានឹងគ្នាមុនពេលអ្នកដោះស្រាយវិវាទចេញសេចក្តីសម្រេច។

៣-ភាគីជម្លោះព្រមព្រៀងគ្នាដកខ្លួនចេញពីការដោះស្រាយវិវាទ។

៤-ភាគីជម្លោះបំពានធ្ងន់ធ្ងរចំពោះបញ្ញត្តិដែលមានចែងក្នុងប្រកាសនេះ។

៥-ភាគីជម្លោះបានទទួលមរណភាព ឬបានរំលត់នីតិបុគ្គលហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង។

**ប្រការ ៣៦.-**

អ្នកដោះស្រាយវិវាទត្រូវបញ្ចប់ការដោះស្រាយវិវាទក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអ្នកដោះស្រាយវិវាទត្រូវបានចាត់តាំង លើកលែងករណីដូចខាងក្រោម÷

១-មានហេតុណាមួយដូចបញ្ញត្តិក្នុងប្រការ ៣៤ នៃប្រកាសនេះ ឬ

២-មានការសម្រេចរបស់អគ្គនាយកនៃ **គ.ម.ក.** តាមសំណើសុំពន្យារពេលរបស់អ្នកដោះស្រាយវិវាទ ឬសំណើសុំពន្យារពេលតាមការព្រមព្រៀងរបស់ភាគីជម្លោះ។

**ប្រការ ៣៧.-**

ក្នុងការចេញសេចក្ដីសម្រេច អ្នកដោះស្រាយវិវាទអាចសម្រេចពីវិវាទ÷

១-តាមការស្រុះស្រួលរបស់ភាគីជម្លោះ។

២-តាមភាពសមហេតុផល សមធម៌ ឬឧត្ដមានុវត្តក្នុងវិស័យមូលបត្រ។

៣-តាមច្បាប់ និងបទប្បញ្ញត្តិជាធរមានដែលយល់ថាអាចអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទ។

**ប្រការ ៣៨.-**

អ្នកដោះស្រាយវិវាទត្រូវចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់នូវចំណុចដូចខាងក្រោម÷

១-អត្តសញ្ញាណភាគីជម្លោះ

២-អង្គហេតុ និងចំណុចវិវាទ

៣-សំអាងហេតុ

៤-ការសម្រេចសេចក្ដី

៥-សំណង សោហ៊ុយចំណាយផ្សេងៗ និងភាគីដែលត្រូវទទួលរ៉ាប់រងបន្ទុកចំណាយ

៦-កាលបរិច្ឆេទដែលភាគីជម្លោះត្រូវអនុវត្តសេចក្ដីសម្រេចរបស់អ្នកដោះស្រាយវិវាទ

៧-កាលបរិច្ឆេទចេញសេចក្ដីសម្រេច

៨-ហត្ថលេខារបស់អ្នកដោះស្រាយវិវាទ ឬក្រុមអ្នកដោះស្រាយវិវាទ។ ក្នុងករណីអ្នកដោះស្រាយវិវាទណាម្នាក់ក្នុងចំណោមក្រុមអ្នកដោះស្រាយវិវាទមានធុរៈក្នុងការចុះហត្ថលេខាលើសេចក្ដីសម្រេច អ្នកដោះ-ស្រាយវិវាទផ្សេងទៀត ត្រូវចុះហត្ថលេខា ដោយចុះនិទ្ទេសអំពីហេតុដែលអ្នកដោះស្រាយវិវាទនោះមិនអាចចុះហត្ថលេខាបាន។

ចំពោះក្រុមអ្នកដោះស្រាយវិវាទ សេចក្ដីសម្រេចត្រូវធ្វើដោយសម្លេងភាគច្រើន។

**ប្រការ ៣៩.-**

សេចក្ដីសម្រេចត្រូវបញ្ជូនទៅឱ្យភាគីជម្លោះក្នុងអំឡុងពេល ៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលចេញសេចក្ដីសម្រេចនោះ។

សេចក្ដីសម្រេចដែលចេញដោយអ្នកដោះស្រាយវិវាទ ចងកាតព្វកិច្ចអនុវត្តចំពោះភាគីជម្លោះដែលជាប្រតិបត្តិករ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនសមភាគីកណ្ដាល ក្រុមហ៊ុនឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាត អាជ្ញាបណ្ណ ឬការទទួលស្គាល់ពី **គ.ម.ក.**។

ភាគីជម្លោះដែលជាវិនិយោគិនត្រូវជូនដំណឹងបញ្ជាក់ពីការយល់ព្រម ឬមិនយល់ព្រមអនុវត្តសេចក្ដីសម្រេច ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេចនោះ។ ករណីភាគីជម្លោះនេះយល់ព្រមអនុវត្តសេចក្ដីសម្រេច ភាគីជម្លោះទាំងអស់ត្រូវចុះហត្ថលេខា ឬផ្ដិតម្រាមដៃលើកិច្ចព្រម-

ព្រៀងនៅចំពោះមុខអ្នកដោះស្រាយវិវាទយ៉ាងយូរក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលភាគីជម្លោះជាវិនិយោគិនជូនដំណឹងពីការយល់ព្រមអនុវត្តសេចក្ដីសម្រេច។

**ប្រការ ៤០.-**

ករណីភាគីជម្លោះជាវិនិយោគិនមិនយល់ព្រមអនុវត្តសេចក្ដីសម្រេចរបស់អ្នកដោះស្រាយវិវាទ ភាគីជម្លោះអាចប្ដឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច។

ប្រតិបត្តិករ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនសមភាគីកណ្ដាល ក្រុមហ៊ុនឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាត អាជ្ញាបណ្ណ ឬការទទួលស្គាល់ពី **គ.ម.ក.** ដែលមិនយល់ព្រមអនុវត្តសេចក្ដីសម្រេចរបស់អ្នកដោះស្រាយវិវាទ ក៏អាចប្ដឹងទៅតុលាការមានសមត្ថកិច្ច អនុលោមតាមមាត្រា៤៦ នៃច្បាប់ផងដែរ។

## ជំពូកទី ៦
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ៤១.-**

ប្រតិបត្តិករ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនសមភាគីកណ្ដាល ក្រុមហ៊ុនឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាត អាជ្ញាបណ្ណ ឬការទទួល-ស្គាល់ពី **គ.ម.ក.** ត្រូវមានខចែងស្ដីពីការដោះស្រាយវិវាទនៅក្នុងកិច្ចសន្យា កិច្ចព្រមព្រៀងអតិថិជន ឬកិច្ច-ព្រមព្រៀងផ្សេងៗទៀតដែលត្រូវធ្វើឡើងនៅក្នុងទំនាក់ទំនងអាជីវកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រ។

**ប្រការ ៤២.-**

ត្រូវចាត់ទុកថាភាគីជម្លោះទទួលបានលិខិតអញ្ជើញ លិខិតជូនដំណឹង កំណត់ហេតុសះជា កំណត់-ហេតុមិនសះជា សេចក្ដីសម្រេច ឬឯកសារពាក់ព័ន្ធផ្សេងៗក្នុងដំណើរការផ្សះផ្សា និងដោះស្រាយវិវាទ ក្នុងករណីបានប្រគល់លិខិតនោះឱ្យភាគីជម្លោះដោយផ្ទាល់ដៃ ឬប្រគល់ដល់កន្លែងធ្វើពាណិជ្ជកម្ម ឬទីលំនៅ ឬអាសយដ្ឋានប្រៃសណីយ៍។ ប្រសិនបើរកកន្លែងទាំងនោះមិនឃើញទេ ក្រោយពីការស្វះស្វែងរកយ៉ាងល្អិតល្អន់រួចមក លិខិតនោះត្រូវចាត់ទុកថាបានទទួលដោយភាគីជម្លោះ ក្នុងករណីបានផ្ញើតាមរយៈលិខិតអនុសិដ្ឋ ឬតាមមធ្យោបាយផ្សេងៗដែលផ្ដល់ហេតុផលថា ពិតជាបានខំប្រឹងប្រែងប្រគល់លិខិតនោះទៅដល់កន្លែងប្រកបពាណិជ្ជកម្ម ឬទីលំនៅ ឬអាសយដ្ឋានរបស់ភាគីជម្លោះដែលស្គាល់ចុងក្រោយបំផុត។

**ប្រការ ៤៣.-**

អ្នកផ្សះផ្សា អ្នកដោះស្រាយវិវាទ ភាគីជម្លោះ អ្នកបកប្រែភាសា អ្នកជំនាញ មេធាវី និងបុគ្គលពាក់ព័ន្ធផ្សេងទៀតក្នុងដំណើរការផ្សះផ្សា ឬដោះស្រាយវិវាទ ត្រូវរក្សាការសម្ងាត់នូវរាល់ព័ត៌មាន ការឆ្លើយឆ្លង

សារអេឡិចត្រូនិច រឿងរ៉ាវដែលបានពិភាក្សា សេចក្ដីស្នើ កំណត់ហេតុ និងឯកសារពាក់ព័ន្ធផ្សេងទៀត ដោយមិនត្រូវបើកបង្ហាញ ឬបកស្រាយ ឬយកទៅផ្សព្វផ្សាយជាសាធារណៈ ទោះធ្វើឡើងតាមរយៈការនិយាយក្ដី ឬការសំដែងក្ដី ឬក្រោមរូបភាពណាមួយក៏ដោយ លើកលែងតែករណីដូចខាងក្រោម÷

១-មានការយល់ព្រមពីភាគីជម្លោះទាំងអស់។

២-តម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៣-ព័ត៌មាន ឬឯកសារទាំងនោះ មិនត្រូវបានបង្ហាញអត្តសញ្ញាណរបស់ភាគីជម្លោះទាំងអស់។

៤-សម្រាប់សិក្សាស្រាវជ្រាវ ឬស្ថិតិនៅ **គ.ម.ក.** ដោយមិនបង្ហាញអត្តសញ្ញាណរបស់ភាគីជម្លោះ។

**ប្រការ ៤៤.-**

មន្ត្រីរបស់ **គ.ម.ក.** អ្នកផ្សះផ្សា និងអ្នកដោះស្រាយវិវាទ ត្រូវរួចផុតពីការទទួលខុសត្រូវទាំងអស់នៅក្នុងការអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិអំណាចដោយសុចរិត ផ្អែកតាមភាពស្មោះត្រង់ដូចមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤៥.-**

សោហ៊ុយចំណាយចំពោះអ្នកបកប្រែភាសា និងអ្នកជំនាញ ជាបន្ទុករបស់ភាគីជម្លោះដែលស្នើសុំ ឬជាបន្ទុករបស់ភាគីជម្លោះក្នុងចំណែកស្មើៗគ្នា ក្នុងករណីអ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទតម្រូវឱ្យមាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយភាគីជម្លោះ។

## ជំពូកទី ៧
## ទណ្ឌកម្ម

**ប្រការ ៤៦.-**

ករណីប្រតិបត្តិករ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនសមភាគីកណ្ដាល ក្រុមហ៊ុនឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាត អាជ្ញាបណ្ណ ឬការទទួលស្គាល់ពី **គ.ម.ក.** មិនអនុវត្តតាមកំណត់ហេតុសះជា ឬសេចក្ដីសម្រេចរបស់អ្នកដោះស្រាយវិវាទ ដូចមានចែងក្នុងប្រការ ៣៩ នៃប្រកាសនេះ ឬកាតព្វកិច្ចដូចមានចែងក្នុងប្រការ ៤៣ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** មិនលើសពីចំនួន ២០០.០០០.០០០ (ពីររយលាន) រៀល និង/ឬទណ្ឌកម្មរដ្ឋបាលពី **គ.ម.ក.** ដូចជា÷

១-ព្រមាន។

២-ដឹកនាំកែតម្រង់។

៣-ដាក់លក្ខខណ្ឌ ឬកំហិតបន្ថែមលើអាជ្ញាបណ្ណ ការអនុញ្ញាត ឬការទទួលស្គាល់។

៤-ព្យួរ ឬដកហូតអាជ្ញាបណ្ណ ការអនុញ្ញាត ឬការទទួលស្គាល់។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ ៤៧.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ ៤៨.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋានអង្គភាពស្ថិតនៅចំណុះឱ្យ **គ.ម.ក.** ប្រតិបត្តិករ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនសមភាគីកណ្តាល ក្រុមហ៊ុនឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

បណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  “ដើម្បីជូនជ្រាប”
- ដូចប្រការ ៤៨
  “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធប្រកាសលេខ ០១២ /១៧ ត.ឋ.ក./ប្រក

## ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧

## ស្តីពី

## កម្រៃសេវារដ្ឋបាល ប្រាក់តម្កល់ និងកម្រៃសេវា

## សម្រាប់អ្នកផ្សះផ្សា និងអ្នកដោះស្រាយវិវាទ

* * * * *

### ១. ប្រាក់តម្កល់សម្រាប់ការផ្សះផ្សា និងការដោះស្រាយវិវាទ

បន្ទាប់ពីចុះកិច្ចព្រមព្រៀងផ្សះផ្សាវិវាទ ភាគីជម្លោះត្រូវដាក់ប្រាក់តម្កល់រៀងខ្លួននៅការិយាល័យទទួលបន្ទុកដោះស្រាយវិវាទនៃ **គ.ម.ក.** ចំនួន ១.៥០០.០០០ (មួយលានប្រាំសែន) រៀល ដែលប្រាក់តម្កល់នេះសម្រាប់ធានាការទូទាត់ចំពោះសោហ៊ុយចំណាយផ្សេងៗ និងចំណាយឥតព្រាងទុកនៅក្នុងដំណើរការផ្សះផ្សា។ ប្រសិនបើក្រោយការទូទាត់ សោហ៊ុយចំណាយមានចំនួនតិចជាងប្រាក់តម្កល់ ប្រាក់តម្កល់ដែលនៅសល់ត្រូវប្រគល់ជូនភាគីជម្លោះ ក្នុងរយៈពេលយ៉ាងយូរ ១៤ (ដប់បួន)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃភាគីជម្លោះទទួលបានកំណត់ហេតុ។

ករណីភាគីជម្លោះមិនសះជាលើចំណុចណាមួយ ភាគីជម្លោះអាចប្តឹងទៅកាន់វេទិកាដោះស្រាយវិវាទរបស់**គ.ម.ក.**។ ភាគីជម្លោះត្រូវដាក់ប្រាក់តម្កល់ជាថ្មីម្តងទៀតរៀងខ្លួននៅការិយាល័យទទួលបន្ទុកដោះស្រាយវិវាទចំនួន ១.៥០០.០០០ (មួយលានប្រាំសែន) រៀល សម្រាប់ធានាការទូទាត់ចំពោះសោហ៊ុយចំណាយផ្សេងៗ និងចំណាយឥតព្រាងទុកនៅក្នុងដំណើរការដោះស្រាយវិវាទ។ ប្រសិនបើក្រោយការទូទាត់ សោហ៊ុយចំណាយមានចំនួនតិចជាងប្រាក់តម្កល់ ប្រាក់តម្កល់ដែលនៅសល់ត្រូវប្រគល់ជូនភាគីជម្លោះ ក្នុងរយៈពេលយ៉ាងយូរ ១៤(ដប់បួន)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃភាគីជម្លោះទទួលបាន សេចក្តីសម្រេចដែលចេញដោយអ្នកដោះស្រាយវិវាទ។

ករណីប្រាក់តម្កល់សម្រាប់ការផ្សះផ្សា ឬការដោះស្រាយវិវាទ មិនអាចទូទាត់សោហ៊ុយចំណាយបាន ភាគីជម្លោះត្រូវទូទាត់សោហ៊ុយចំណាយបន្ថែមតាមជាក់ស្តែង។

### ២. កម្រៃសេវារដ្ឋបាលសម្រាប់ការផ្សះផ្សា ឬការដោះស្រាយវិវាទ

ភាគីជម្លោះត្រូវបង់កម្រៃសេវារដ្ឋបាលតាមកម្រិតនៃកម្រៃសេវាដែលត្រូវបានកំណត់ដូចខាងក្រោម÷

| តម្លៃដែលជាកម្មវត្ថុនៃបណ្តឹង (គិតជាប្រាក់រៀល) | | កម្រិតនៃកម្រៃសេវា | | | | |
|---|---|---|---|---|---|---|
| តិចជាង | ៨០.០០០.០០០ | ១.០០០.០០០ | | | | |
| ចាប់ពី | ៨០.០០០.០០០ ដល់ ១៦០.០០០.០០០ | ១.០០០.០០០ | + | ១,២៥% | នៃចំនួនដែល | ៨០.០០០.០០០ |
| ចាប់ពី | ១៦០.០០០.០០១ ដល់ ២៤០.០០០.០០០ | ២.០០០.០០០ | | | លើសពី | ១៦០.០០០.០០០ |

| | | | | | | |
|---|---|---|---|---|---|---|
| ចាប់ពី | ២៤០.០០០.០០១ ដល់ ៣២០.០០០.០០០ | ៣.០០០.០០០ | | | | ២៤០.០០០.០០០ |
| ចាប់ពី | ៣២០.០០០.០០១ ដល់ ៤០០.០០០.០០០ | ៤.០០០.០០០ | | | | ៣២០.០០០.០០០ |

ករណីតម្លៃដែលជាកម្មវត្ថុនៃវិវាទសម្រាប់ការផ្សះផ្សាលើសពី ៤០០.០០០.០០០ (បួនរយលាន) រៀល កម្រៃសេវារដ្ឋបាលត្រូវបានកំណត់យក ៦.៥០០.០០០ (ប្រាំមួយលានប្រាំសែន) រៀល។

## ៣. កម្រៃសេវាសម្រាប់អ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទ

កម្រៃសេវាសម្រាប់អ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទ ត្រូវកំណត់តាមកម្រិតអត្រាជាភាគរយដែលប្រែប្រួលទៅតាមតម្លៃនៃកម្មវត្ថុនៃបណ្ដឹង និងកំណត់ស្របតាមតារាងខាងក្រោម÷

| តម្លៃដែលជាកម្មវត្ថុនៃបណ្ដឹង (គិតជាប្រាក់រៀល) | | កម្រិតនៃកម្រៃសេវា | | | | |
|---|---|---|---|---|---|---|
| តិចជាង | ៨០.០០០.០០០ | ២.០០០.០០០ | | | | |
| ចាប់ពី | ៨០.០០០.០០០ ដល់ ១៦០.០០០.០០០ | ២.០០០.០០០ | + | ១% | នៃចំនួនដែលលើសពី | ៨០.០០០.០០០ |
| ចាប់ពី | ១៦០.០០០.០០១ ដល់ ២៤០.០០០.០០០ | ២.៨០០.០០០ | | ០,៧ % | | ១៦០.០០០.០០០ |
| ចាប់ពី | ២៤០.០០០.០០១ ដល់ ៣២០.០០០.០០០ | ៣.៣៦០.០០០ | | ០,៥ % | | ២៤០.០០០.០០០ |
| ចាប់ពី | ៣២០.០០០.០០១ ដល់ ៤០០.០០០.០០០ | ៣.៧៦០.០០០ | | ០,៣ % | | ៣២០.០០០.០០០ |

ករណីតម្លៃដែលជាកម្មវត្ថុនៃវិវាទសម្រាប់ការផ្សះផ្សាលើសពី ៤០០.០០០.០០០ (បួនរយលាន) រៀល កម្រៃសេវាសម្រាប់អ្នកផ្សះផ្សាត្រូវបានកំណត់យក ៤.៨០០.០០០ (បួនលានប្រាំបីសែន) រៀល។

ការគណនាអត្រានៃកម្រៃសេវាត្រូវបានគិតតាមរបៀបដូចខាងក្រោម÷

ឧទាហរណ៍ទី ១÷ ករណីដែលកម្មវត្ថុនៃបណ្ដឹងចំនួន ៩០.០០០.០០០ រៀល

កម្រៃសេវាដែលទទួលបាន = ២.០០០.០០០ + (១០.០០០.០០០ X ១%)

= ២.១០០.០០០ រៀល

ឧទាហរណ៍ទី ២÷ ករណីដែលកម្មវត្ថុនៃបណ្ដឹងចំនួន ២០០.០០០.០០០ រៀល

កម្រៃសេវាដែលទទួលបាន = ២.៨០០.០០០ + (៤០.០០០.០០០ X ០,៧%)

= ៣.០៨០.០០០ រៀល